ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋាន

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា
## បម្រើការងារនៅនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

នាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន **០៥** រូប ទៅតាមជំនាញ និង លក្ខខណ្ឌដូចខាងក្រោម ÷

- ជំនាញផ្នែកសរសេរកម្មវិធីកុំព្យូទ័រ (Programmer) ចំនួន **០១** រូប
  - ត្រូវមានសញ្ញាបត្របរិញ្ញាបត្រឡើងទៅផ្នែកព័ត៌មានវិទ្យា ឬវិទ្យាសាស្ត្រកុំព្យូទ័រ ឬប្រហាក់ប្រហែល
  - មានជំនាញក្នុងការសរសេរកូដភាសា .Net Programming (C#, Visual Basic) ឬ Java ឬ ASP.Net ឬ PHP Programming ឬ ផ្សេងទៀត
  - មានចំណេះដឹងច្បាស់លាស់ផ្នែក Object-Oriented Programming
  - មានចំណេះដឹងផ្នែក Database Management System
  - ធ្លាប់មានបទពិសោធន៍បង្កើតកម្មវិធីកុំព្យូទ័រមួយចំនួនដែលដំណើរការលើប្រព័ន្ធដំណើរការ Windows ឬ Web-based (សូមភ្ជាប់ជាឯកសារយោង) ។
- ជំនាញផ្នែកគំនូរជីវចល ចំនួន **០២** រូប
  - ត្រូវមានសញ្ញាបត្របរិញ្ញាបត្រឡើងទៅផ្នែកពហុផ្សព្វផ្សាយ និង គំនូរជីវចល (Multimedia and Animation) ឬប្រហាក់ប្រហែល
  - មានគំនិតច្នៃប្រឌិត និងប៉ិនប្រសប់ក្នុងការបង្កើតថ្មី
  - មានជំនាញសិល្បៈ និងគំនូរ (លើកទឹកចិត្តចំពោះអ្នកមានបទពិសោធន៍គូរគំនូរដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រ)
  - មានចំណេះដឹងក្នុងការប្រើប្រាស់កម្មវិធី Adobe Photoshop, Adobe In-Design, Adobe Illustration និង Autodesk Maya ជាដើម
  - ធ្លាប់មានបទពិសោធន៍ផលិតគំនូរជីវចល (សូមភ្ជាប់មកជាមួយនូវឯកសារយោង)។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០០៦៣ ទូរសារ : ៨៥៥-២៣-៤៣០០៦៣
Phone : 855-23-430 063 Fax : 855-23-430 063

- ជំនាញផ្នែកទំនាក់ទំនងសាធារណៈ ចំនួន **០១** រូប
  - មានសញ្ញាបត្របរិញ្ញាបត្រឡើងទៅផ្នែកទំនាក់ទំនងទូទៅ និង ទំនាក់ទំនងសាធារណៈ (Communication and Public Relation) ឬផ្នែកទីផ្សារ ឬប្រហាក់ប្រហែល
  - មានភាពប៉ិនប្រសប់ក្នុងការប្រាស្រ័យទាក់ទង និងការនិយាយជាសាធារណៈ
  - មានសមត្ថភាពរៀបចំយុទ្ធសាស្ត្រ និង យុទ្ធនាការផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាព។
- ផ្នែក Copywriter ចំនួន **០១** រូប
  - មានសញ្ញាបត្របរិញ្ញាបត្រឡើងទៅផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មាន (Media and Journalism) ឬ ភាសាអង់គ្លេស
  - មានជំនាញក្នុងការបកប្រែទាំងការនិយាយ និងការសរសេរ ពីភាសាខ្មែរទៅអង់គ្លេស និងភាសាអង់គ្លេសទៅភាសាខ្មែរ។

**<u>លក្ខខណ្ឌជ្រើសរើសរួម</u>**

១. ត្រូវមានសញ្ញាបត្របរិញ្ញាបត្រឡើង ទៅតាមជំនាញនីមួយៗខាងលើ

២. ត្រូវមានចំណេះដឹងភាសាអង់គ្លេសសមរម្យ

៣. ត្រូវមានឆន្ទៈ និង មនសិការក្នុងការបំពេញការងារជូនស្ថាប័នរដ្ឋ និង មានសីលធម៌ក្នុងការរស់នៅល្អ

៤. ត្រូវមានការព្យាយាម និង តស៊ូបំពេញការងារក្រោមលក្ខខណ្ឌពិបាក និង មានអត្តចរិតស្លូតបូត ស្លូតត្រង់ និង ម៉ឺងម៉ាត់

៥. បេក្ខជនត្រូវភ្ជាប់អត្តសញ្ញាណប័ណ្ណ ជាជនជាតិខ្មែរ មានសញ្ជាតិខ្មែរ និង មានអាយុមិនលើសពី ៣០ ឆ្នាំ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេប និង ឯកសារពាក់ព័ន្ធមកនាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានអាសយដ្ឋានផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ អាគារ "ខ" ជាន់ទី៦ ឬផ្ញើតាមរយៈអ៊ីមែល itd.info@mef.gov.kh ឱ្យបានមុនថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៦។

ទំនាក់ទំនងលេខទូរស័ព្ទ ÷ ០១២ ៦២៩ ៩៥៦

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៦